# ខ្មែរប៉ុស្តិ៍ ឆ្នេរខាងកើត
# THE KHMER POST EAST COAST
The Cambodian-American Biweekly News
Email : Khmerpostusa@gmail.com
Cell : (267) 253-3947
VOLUME 04 ISSUE 55 March 12th - 25th, 2010


# រំលឹកប្រវត្តិថ្ងៃ១៨ មីនា ឆ្នាំ១៩៧០



**ដោយ : ពិន សំខុន**

•••៣០ឆ្នាំហើយ ដែលប្រទេសកម្ពុជាបានប្តូរប្រវត្តិច្រើនពាន់ឆ្នាំរបស់ខ្លួន ពីព្រះរាជាណាចក្រកម្ពុជាមករបបសាធារណៈជាលើកដំបូងបង្អស់ នាថ្ងៃ១៨ ខែមីនា ឆ្នាំ១៩៧០ ។ តើ៣០កន្លងមកនេះ អ្វីខ្លះដែលបានវិនាស ហើយអ្វីខ្លះដែលបាននៅសេសសល់ជាសម្បត្តិ ដែលខ្ញុំយល់ថា គួរយកពេលបន្តិចមកពិចារណាទៅលើព្រឹត្តិការណ៍ដែលបានប្តូរប្រទេស និងពលរដ្ឋដ៏ធំធេងមួយរបស់កម្ពុជា នាពេលដែលជម្លោះរវាងយួនកុម្មុយនិស្តខាងជើង និងយួនលោកសេរីខាងជើងវាយដណ្តើមឥទ្ធិពលរបស់ខ្លួនសោះ តែបាននាំកម្ពុជាឱ្យធ្លាក់ក្នុងភ្លក់ភ្លើងសង្គ្រាមជាមួយនឹងគេបាន ។



រឿងនេះផ្តើមឡើងនៅពេលបារាំងអាណានិគមបានដកខ្លួនចេញពីឥណ្ឌូចិន ឆ្នាំ១៩៥៣ បានសន្យា និងយួនខាងជើង និងយួនខាងត្បូងថានិងរៀបចំឱ្យមានការបោះឆ្នោតបង្រួបបង្រួមវៀតណាមតែមួយជូនប្រទេសនេះ តែសហរដ្ឋអាមេរិកមើលឃើញការបោះឆ្នោតផ្តល់ប្រៀបដ៏ច្រើនឱ្យកុម្មុយនិស្ត ក៏ហក់ចូលមកជួយយួនខាងត្បូង ជំនួសបារាំងដែលបង្ហាញសញ្ញាចាញ់ឥទ្ធិពលកុម្មុយនិស្តនៃចម្បាំងចុងក្រោយបង្អស់ នាសមរភូមិ ឌៀន បៀនភូ ។ ចម្បាំងយួនខាងត្បូង-សហរដ្ឋអាមេរិកតទល់និងយួនខាងជើង-ចិន-រុស្ស៊ី ពុំអាចធ្វើឱ្យការសន្យារបស់បារាំងអនុវត្តទៅបានផ្តល់លេសឱ្យយួនខាងជើងក្នុងនាមម្ចាស់ទឹកដីមានកម្លាំង និងវាយបរទេសសហរដ្ឋអាមេរិកបណ្តេញឱ្យចេញវៀតណាមបានយ៉ាងខ្លាំងក្លា ។

រីឯប្រទេសកម្ពុជា ក្រោមការដឹកនាំដ៏ផ្តាច់មុខរបស់សម្តេចនរោត្តមសីហនុ ជាស្តេចផង ជាព្រះប្រមុខរដ្ឋផង បានផ្តើមនយោបាយទប់ទល់សង្គ្រាមស្រុកយួនដោយរបបអព្យាក្រិត្យមួយងាកវេទៅរកប្រទេសចិន ចាប់ពីពេលបានជួបនាយករដ្ឋមន្ត្រី ជូ អេនឡាយ នៃកិច្ចប្រជុំបានដុង នៅប្រទេសឥណ្ឌូនេស៊ី នៅឆ្នាំ១៩៥៥ ។ សង្គ្រាមនៅស្រុកយួន បានពង្រឹងរបបសីហនុ និងសង្គមរាស្ត្រនិយមរបស់ព្រះអង្គបានរឹងមាំ តែរបបនេះ បានផ្តើមប្រឆាំងនិងទស្សនៈប្រជាធិបតេយ្យរបស់លោកសេរី និងទស្សនៈប្រឆាំងរាជានិយមរបស់កុម្មុយនិស្តផងដែរ - នេះជាសង្គ្រាមក្នុងកម្ពុជា ដែលសីហនុបានចិញ្ចឹមដោយអចេតនា ។

នៅស្រុកខ្មែរ ទស្សនៈសេរី និងស្នេហាជាតិបានដុះដាលយ៉ាងលឿនក្នុងចំណោមរាស្ត្រ និងអ្នកសិក្សាដែលធ្វើឱ្យដំណើរនៃរបបសីហនុនិយមដើរដោយលំបាកពុំអាចទប់ទល់បានទៀតទេ ។ (**តទៅទំព័រទី ០៤**)

# លោកអ្នកដឹងដែរឬទេ?

**I-មានការបង្រៀនភាសាខ្មែរ ដោយអ្នកគ្រូ ចាន់ថា ជុំ**

នៅសមាគមខ្មែរ រៀងរាល់ថ្ងៃអាទិត្យ វេលាម៉ោង ១០ព្រឹក ។



អ្នកគ្រូ ចាន់ថា ជុំ កំពុងបង្រៀនភាសាខ្មែរ

## II- ក្រុមជំរឿនប្រជាជន Census :

ក្រុមជំរឿនប្រជាជនកំពុងត្រូវការអ្នកធ្វើការ ដើម្បីរាប់ប្រជាជនតាមផ្ទះនីមួយៗ ។ នេះជាឱកាសដ៏សំខាន់មួយដែលគួរដឹងថា "ចំនួនប្រជាពលរដ្ឋពិតប្រាកដរបស់សហគមន៍ គឺជាជំនួយក្នុងការចែកថវិការដ្ឋ ដើម្បីជួយអភិវឌ្ឍន៍សហគមន៍នោះឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធិភាព" ។

ដូច្នេះសូមពលរដ្ឋទាំងអស់ចូលរួមបំពេញបែបបទដែលក្រសួង Census ផ្ញើទៅផ្ទះនីមួយៗឱ្យបំពេញ ។ លោកអ្នកមិនគួរអល់ឯកអ្វីទេ ដោយក្រសួងនេះ បានសច្ចាថា មិនយកព័ត៌មានដែលជាចំនួនប្រជាពលរដ្ឋនេះទៅផ្តល់ឱ្យអង្គការ អាជ្ញាធរណាមួយផ្សេងទៀតទេ ។ ខែមីនានេះ លោកអ្នកទទួលលិខិតសម្រាប់បំពេញឈ្មោះអ្នកនៅផ្ទះជាមួយគ្នា ដែលគេសុំឱ្យផ្ញើត្រឡប់មកវិញជាបន្ទាន់ ។ បើសិនជាលើកអ្នកមិនបានទទួលប័ណ្ណពីក្រសួង Census ទេនោះ នៅដើមខែមេសា ក្រុមជំរឿននឹងមកគោះទ្វារឱ្យបំពេញលិខិតនោះដល់ផ្ទះតែម្តង។ សូមលោកអ្នកនាំគ្នាបំពេញភារកិច្ចជាមួយក្រុមជំរឿននេះ ដើម្បីជួយសហគមន៍ខ្លួនឯងឱ្យបានគ្រប់គ្នា ។

## III. រដ្ឋផែនស៊ីវេនា បំរុងដំឡើងពាក់ :

ខ្វះថវិកាសំរាប់គ្រប់គ្រងក្រុង រដ្ឋនេះមានគម្រោងយកពន្ធលើភេសជ្ជៈ សូដា និងសម្រាមដែលប្រមូលចោលរាល់ព្រឹក ។

**១-** សូដា មានជាតិផ្អែម, ធ្វើឱ្យធាត់មនុស្ស, ឈឺច្រើន, ព្យាបាលអស់ប្រាក់ច្រើន, យកពន្ធលើ សូដា និងបន្ថយការព្យាបាលដ៏ថ្លៃ ។

**២-** ពន្ធលើសម្រាមគ្រប់ផ្ទះ គឺ១ផ្ទះតម្លៃប្រមាណ ៣៥០ដុល្លារក្នុង១ឆ្នាំ ។ ករណីសម្រេចយកពន្ធទាំងពីរមុខនេះ បានទទួលការទិទាន និងទាមទារឱ្យប្តូរទិសដៅពីព្រោះប៉ះពាល់ដល់អ្នកក្រីក្រច្រើនគ្នា ដែលពុំមានលុយបង់ ។ ក្នុងពេលនេះ សាលាក្រុងកំពុងទុកពេលឱ្យពលរដ្ឋតវ៉ា និងផ្តល់យោបល់ពីវិធីរកលុយជូនក្រុងឱ្យអាចបំរើពលរដ្ឋបាន ៕ **-ខ្មែរប៉ុស្តិ៍-**

សូមអញ្ជើញលោកអ្នកអានអត្ថបទជាភាសាអង់គ្លេស នៅទំព័រខាងក្នុង ដែលបានដកស្រង់ និងទទួលការអនុញ្ញាតឱ្យចុះផ្សាយពីសារព័ត៌មាន The Cambodia Daily នៅប្រទេសកម្ពុជា ៕

## មាតិការឿង — ទំព័រ


១- សម រង្ស៊ី ប្រើផែនទីក្លែងក្លាយ....................ទំព័រទី០៣
២- តើសព្វថ្ងៃអ្នកណាជាម្ចាស់....................ទំព័រទី០៥
៣- អត្ថបទមនោសញ្ចេតនា, តែពាំពែង និងរញ្ជួយដីនៃហៃទី.....ទំព័រទី០៦
៤- The Cambodia Daily ....................ទំព័រទី០៨-១៣
៥- ហឹង្សានៅសាលាហ្វីឡាដែលហៀ និងពាណិជ្ជកម្មនាំចេញ .......ទំព័រទី០៩
៦-ខ្មែរមានពូជ....................ទំព័រទី១៤
៧-នាទីប្រវត្តិសាស្ត្រ និងនាទីព្រះពុទ្ធសាសនា....................ទំព័រទី១៥





# សម រង្ស៊ី ប្រើផែនទីក្លែងក្លាយមែនឬ? លោក ស៊ាន ប៉េងសែ ឆ្លើយសំនួរខ្មែរប៉ុស្តិ៍


លោក ហ៊ុន សែន


លោក សម រង្ស៊ី

•••**មាជ សុវណ្ណារ៉ា :** ក្នុងនាមកាសែតខ្មែរប៉ុស្តិ៍ ខ្ញុំបាទសូមជម្រាបសួរលោកអតីតមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ហើយក៏ជាប្រធានគណៈ-កម្មាធិការកិច្ចការព្រំដែនកម្ពុជា ដែលមានទីស្នាក់ការនៅប្រទេសបារាំង ។ ខ្ញុំបាទសូមជម្រាបសួរបាទ !

**ស៊ាន ប៉េងសែ :** សូមជម្រាបសួរ !

**មាជ សុវណ្ណារ៉ា :** លោក ស៊ាន ប៉េងសែ លោកដឹងហើយថា រដ្ឋាភិបាលបានប្ដឹងលោក សម រង្ស៊ី មួយករណីទៀតរឿងព្រំដែនដោយ លោក វ៉ា គឹមហុង ដែលជាទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការព្រំដែនរបស់រដ្ឋាភិបាលលោក ហ៊ុន សែន កាលពីម្សិលមិញ (ទី14 កុម្ភៈ) លោកបានធ្វើសន្និសីទកាសែតមួយ ។ សន្និសីទកាសែតនោះក្នុងបំណងថា ដាក់ប្ដឹងទៅលោក សម រង្ស៊ី ពីការក្លែងបន្លំឯកសារទាក់ទងទៅនឹងព្រំដែន ។ លោក វ៉ា គឹមហុង ថា ផែនទីរបស់លោកដែលលោកបង្ហាញក្នុងសន្និសីទកាសែតនោះ លោកថា មិនមានបានបាត់បង់ទឹកដីដូច ដែលលោក សម រង្ស៊ី បានបង្ហាញតាមផែនទីរបស់គាត់ទេ ។

**ស៊ាន ប៉េងសែ :** បាទ ! សូមអរគុណម្ដងទៀត ។ ប៉ុន្តែដល់ទៅមែនទែនទៅត្រូវតែ លោក សម រង្ស៊ី ឆ្លើយទៅអាជ្ញាធរក្រុងភ្នំពេញទេ ។ ប៉ុន្តែខ្ញុំឆ្លើយជំនួសគាត់ទេ គាត់ដឹងច្បាស់លាស់ណាស់ គាត់មុននឹងនិយាយអ្វី គាត់រៀនសូត្រ និងមើលផែនទីច្បាស់លាស់ដែរ បានជាគាត់ហ៊ាន និយាយអ៊ីចឹង នេះទី1 ។ ចំណែកខ្ញុំវិញលោកឱ្យ ខ្ញុំនិយាយនោះជាអ្នកអាជ្ញាកណ្ដាល ហើយខ្ញុំធ្លាប់ធ្វើផែនទីដែរ ។ ហើយតាមដែលខ្ញុំដឹងមក គឺមិនមែននិយាយកាន់ជើងអ្នកនេះ អ្នកនោះ គឺនិយាយត្រឹមតែដើម្បីការពារបូរណភាពទឹកដី ។ លោក សម រង្ស៊ី ដែលលោកនិយាយនោះ គឺត្រូវពីព្រោះលោកយកផែនទីឆ្នាំ1952 ដែលបារាំងទុកឱ្យ ហើយព្រះករុណាបានយកទៅតម្កល់នៅអង្គការសហប្រជា-ជាតិហ្នឹង ។ ហើយគាត់លើកដាក់ផែនទីថ្មីមួយទៀតនោះថាជា Google ជាផែនទីអាមេរិកាំងខ្នាត 1/50,000 គឺជាការប្រៀបផ្ទឹមទេ គាត់និយាយហើយ និយាយទៀតថា នេះជាការផ្ទឹមនៅក្នុងផែនទីដើមឆ្នាំ 1952 ហ្នឹង វាបោះបង្គោលចូលទៅក្នុងស្រុកខ្មែររួចទៅហើយ ដែលខាតបង់ខាងខ្មែរនោះ ។ ហើយគាត់ដាក់ផែនទី2 មកទៀត គឺថាជាផែនទីបរទេសក៏ដោយ ហើយវាមានការខុសខ្លះជាមួយផែនទីដើមក៏ដោយ ក៏ទឹកដីខ្មែរវាប្រហាក់ប្រហែលគ្នាទេ ហើយធំបំផុត គឺតម្រុយបោះហ្នឹងទៅលើដីខ្មែរទាំងអស់ ។

ចំណែករដ្ឋាភិបាលប្រើផែនទីដែល ខ្ញុំនិយាយហ្នឹង 1- ជាផែនទីដែលបារាំងទុកឱ្យឆ្នាំ 1952 យក26ផ្ទាំង ពីព្រោះនៅក្នុងផែនទីនោះវា មានជាង120ផ្ទាំង ហើយនៅក្នុងខេត្តស្វាយរៀង មាន4ផ្ទាំង ប៉ុន្តែក្នុងការធ្វើព្រំប្រទល់ដែននោះ ដែលគេជជែកសព្វថ្ងៃគេយក26ផ្ទាំង តាំងពីព្រំប្រទល់ដែនដី ខ្មែរ-លាវ-យួន ខាងខេត្តរតនគិរី រហូតដល់ខេត្តកំពត គឺត្រឹមត្រូវហើយ ប៉ុន្តែដែលមិនត្រឹមត្រូវនោះ ហើយដែលគណៈកម្មការមិនព្រម គឺគាត់យកផែនទីអាមេរិកាំងខ្នាត 1/50.000 ហើយនិងខ្នាត 1/50.000នៃផែនទីរបស់យួនសព្វថ្ងៃនេះ គឺផែនទីឆ្នាំ1967 អាមេរិកាំង ហើយផែនទី 1970 គឺរបស់ទ័ពយួនវាយក 40ផ្ទាំងយកមកប្រើទាំងអស់ទៀត ដូច្នេះវាខុសហើយ ។ អ៊ីចឹងហើយបានជាយួនឱ្យខាងខ្មែរមកបោះបង្គោលចូលនៅក្នុងដីខ្មែរ ពីព្រោះគាត់យកផែនទីគាត់ ប្រសិនណាយកផែនទីដែលបារាំងទុកឱ្យវាត្រឹមត្រូវដូចលោក សម រង្ស៊ី និយាយ ហើយគាត់យកផែនទី2ទៅទៀត ។ អាហ្នឹងថាសម្លកកូរយើងយកមកមានបី គឺវាខុសគ្នាទាំងអស់ រួចផែនទីអាមេរិកាំងល្អហើយ វាធ្វើតាមស៊ីតតាលីបតាមអ៊ីនឹង ។ ប៉ុន្តែគាត់ពុះព្រំប្រទល់ដែនខ្មែរមិនដែលទទួលស្គាល់ទេ ហើយខ្មែរទទួលស្គាល់ គឺផែនទីតែមួយទេ ហើយខ្មែរយកតែផែនទីនោះមកប្រើតាំងពីដើមរហូតមកដល់ឥឡូវ ។ ប៉ុន្តែគណៈកម្មការនៅស្រុកខ្មែរធ្វើខុស ដោយយកសន្ធិសញ្ញាឆ្នាំ1955 មកធ្វើតាម ហើយបោះបង្គោលនេះឯង នេះគឺខុសហើយ ។ ហើយខ្ញុំសូមជម្រាបកាលដែលក្ដីយើងឈ្នះហ្នឹង ពេលនេះសូមបើកវង់ក្រចកបន្តិច ដែលយើងឈ្នះក្ដីនៅឯតុលាការក្រុងឡាអេ ពីរឿងប្រាសាទព្រះវិហារ ដោយយោងតាមផែនទីដែលបារាំងទុកឱ្យទេ ។ សៀមបានគូសផែនទីមួយទៀតដែលសៀមទុកឱ្យហ្នឹង ខ្នាត 1/50.000ដូចអាមេរិកាំងអ៊ីចឹងដែរ ជំនាន់នោះ គឺចង់ឱ្យខ្មែរយកផែនទីនេះមកពិនិត្យ ប៉ុន្តែខ្មែរមិនព្រម អ៊ីចឹងបានជាខ្មែរឈ្នះ ហើយសព្វថ្ងៃហ្នឹងសៀមត្រូវតែគោរព ។

**មាជ សុវណ្ណារ៉ា :** ហេតុដូចម្ដេចបានជាអាមេរិកាំងធ្វើឱ្យមានបញ្ហាយកផែនទីហ្នឹង នាំឱ្យមានការច្របូកច្របល់មកដល់ឥឡូវប្រទេសសៀម ប្រទេសយួន អីហ្នឹង គឺគេអត់ទទួលស្គាល់ផែនទីដែលយើងឈ្នះក្ដីដោយតុលាការក្រុងឡាអេ ក្នុងឆ្នាំ1952, 1962 វាយ៉ាងម៉េចដែរ ! ?

**ស៊ាន ប៉េងសែ :** បាទ ! ផែនទីមិនត្រូវរូវគ្នា គឺមាន2ដំណាក់កាល ។ ផែនទីសៀមដូចខ្ញុំបានជម្រាបហើយ គឺសៀមហ្នឹងគាត់ធ្វើជាឯកតោភាគី ក្រោយមកជំនាន់ដើមហ្នឹងគាត់ទទួលស្គាល់ហើយ ផែនទីបារាំងទុកឱ្យក្នុងឆ្នាំ 1904, 1907 សៀម បានទទួលស្គាល់គ្រប់ ហើយគ្មានប្រកែកថាមិនត្រឹមត្រូវទេ គាត់ទទួលស្គាល់ ហើយអរគុណគេថែមទៀត ។ ហើយយើងយកផែនទីហ្នឹងទៅដាក់នៅក្នុងតុលាការអន្តរ -ជាតិគាត់ក៏ទទួលស្គាល់ដែរ ។ ប៉ុន្តែដល់ចាញ់មកហើយបានគាត់ធ្វើថ្មីទៀត គឺ 1/50.000 ហើយពេលដែលប្រជុំគ្នានៅក្នុងឆ្នាំ 1954 គាត់មកកាន់កាប់ព្រះវិហារពេលដែលខ្មែរយើងបានឯករាជ្យមិនទាន់ដល់មួយឆ្នាំផង ។ រួចហើយយើងបានប្ដឹងអីហើយ ប៉ុន្តែមុនហ្នឹងប្ដឹងគ្រាន់តែមិនទាន់ដាក់ទៅតុលាការអន្តរជាតិទេ គឺប្ដឹងតាមអង្គការសហប្រជាជាតិ គឺថាឱ្យយើងជជែកគ្នាអ៊ីចឹងទៅ ។ ហើយយើងបានជជែកគ្នា រហូតដល់ឆ្នាំ1958 ហើយការជជែកគ្នាហ្នឹង សៀមសូមឱ្យខ្មែរយកផែនទីគាត់ដែលបានគូសមក1/50.000យកមកមើលផង តែខ្មែរយើងមិនព្រម ខ្មែរយើងបានទទួលផែនទីពេលដែលខ្មែរ យើងមានការត្រួតត្រាពីអាណានិគមបារាំង គាត់ឱ្យផែនទីហ្នឹងឱ្យយើង ហើយយើងគ្មានផែនទីណាក្រៅពីផែនទីដែលសៀមទទួលស្គាល់នោះទេ ។ ដូច្នោះបានជាយើងឈ្នះ យើងមិនព្រមទទួលស្គាល់យកផែនទីដែលសៀមស្នើឱ្យខ្មែរយើងមើលនោះទេ ។ ប្រសិនណាបើយើងយកផែនទីដែលសៀមយកមកប្រើហ្នឹងវាអត់ត្រូវច្បាប់ទេ ពីព្រោះបារាំងទុកឱ្យយើងតែប៉ុណ្ណឹង ។ ចំណែកផ្នែកខាងឥណ្ឌូចិននោះវិញ ជាមួយយួន ជាមួយលាវដូចគ្នាអ៊ីចឹង យួនក៏ទទួលស្គាល់លាវ សៀម ក៏ទទួលស្គាល់ហ្នឹង គឺផែនទីខ្នាត 1/100.000 ដែលយើងប្រើរហូតដល់ឆ្នាំ1955 ពីព្រោះពេលនោះខ្មែរយើងបានឯករាជ្យហើយ យួនក៏បានឯករាជ្យ គេឈប់បោះពុម្ពតទៅទៀតហើយ ដូច្នោះយើងយកផែនទីនោះមក ។ ហើយក្នុងទសវត្សឆ្នាំ60ដែលព្រះករុណាលោកធ្វើនាយករដ្ឋមន្ត្រីជំនាន់នោះ គាត់បានយកផែនទីហ្នឹងដាក់ទៅតម្កល់នៅអង្គការសហប្រជាជាតិ ។ ហើយផែនទីហ្នឹងហើយដែលក្នុងទសវត្សឆ្នាំ60 យើងបានឱ្យបរទេសដែលគេទទួលស្គាល់មានទាំងពួកយៀកកុងពួកយៀកមិញ គេទទួលស្គាល់ ហើយជំនាន់នោះទទួលស្គាល់បូរណភាពទឹកដីសព្វថ្ងៃ ហើយដែលក្រោយមកឆ្នាំ1970 អាមេរិកាំងក៏ទទួលស្គាល់ហើយដែរ បារាំង ចិន រុស្ស៊ីក៏ គេទទួលស្គាល់ដែរ ។ ដូច្នោះគឺផែន ទីហ្នឹងហើយ ដែលយើងត្រូវយកមកប្រើ ។ ហើយការដែលមិនត្រឹមត្រូវនោះ គឺគាត់ទទួលឱ្យខ្មែរយើងយកផែនទីអាមេរិកាំងឆ្នាំ1967 ដែលគាត់ធ្វើចម្បាំង ហើយហ្នឹងផែនទីយួនដែលគាត់កំពុងធ្វើនៅក្នុងឆ្នាំ1970 ចំនួន40ផ្ទាំងដើម្បីយកមកធ្វើផែនទីដែលជាផែនទីដែលត្រូវតែខ្មែរទទួលស្គាល់គេនឹងបោះពុម្ពចែកទៅទៀត ហើយខ្ញុំជម្រាបថា អាមេរិកាំងគាត់ធ្វើហ្នឹងផែនទីច្បាស់លាស់ណាស់ ហើយគាត់គិតថា មិនមែនជាផែនទីសម្រាប់ឱ្យខ្មែរ ទទួលស្គាល់ទេ សម្រាប់ច្បាំងព្រំប្រទល់ដែន ។ គឺអាមេរិកាំងគាត់

(តទៅទំព័រទី ១៦)

## ប័ណ្ណទទួលសេវាបកប្រែភាសា-ទីក្រុងហ្វីឡាដែលហ្វៀ

**ទីក្រុងហ្វីឡាដែលហ្វៀ ការពារសិទ្ធិពលរដ្ឋដែលមិនចេះ និយាយ សរសេរ អាន ឬ មិនយល់ភាសាអង់គ្លេស ។ លោកអ្នកអាចហៅរកអ្នកបកប្រែជូនបានដោយឥតគិតថ្លៃ នៅពេលលោកអ្នកត្រូវការជំនួយការ ឬព័ត៌មានពីភ្នាក់ងារក្រុង ។**

For interpreter services on the telephone :
សំរាប់សេវាបកប្រែតាមទូរស័ព្ទចុចលេខ ៣-១.១.-សំរាប់ជំនួយបន្ទាន់ ចុច ៩-១-១

For interpreter services at a City office:
សំរាប់សេវាបកប្រែនៅការិយាល័យក្រុង សូមបង្ហាញប័ណ្ណភ្ជាប់នៅខាងក្រោម ដើម្បីឱ្យរកអ្នកបកប្រែជូន ដោយមិនយកកំរៃ

You can make a complaint if you do not receive assistance in your language :
បើគ្មាននរណាជួយ លោកអ្នកអាចតវ៉ា ដោយចុចលេខ ៣-២-១.១- ឬក៏ទៅ
ការិយាល័យ Human Relation លេខ 601 Walnut St. Suite 300s

Remove the card below and use it when requesting language services at a City of Philadelphia agency. Keep this card with you at all times.

**I speak Cambodian.**

**I need assistance in Cambodian. Please make note of my spoken language in your records.**

The City of Philadelphia requires City agencies to ensure equal access to their programs. For information about City government services or to make a complaint with the Philadelphia Commission on Human Relations, dial 3-1-1.

philly311 **DIAL 3-1-1**

Human Relations

GLOBAL PHILADELPHIA

philly311

# A.B.C MONEY TRANSACTION, INC

# ក្រុមហ៊ុនផ្ញើប្រាក់ A.B.C



## តម្លៃសំរាប់ផ្ញើទៅស្រុកខ្មែរ

| | | ភ្នំពេញ | តាមខេត្ត |
|---|---|---|---|
| ផ្ញើ $100 | យកកម្រៃ | $4.50 | $5.50 |
| $200 | យកកម្រៃ | $9.00 | $11.00 |
| $300 | យកកម្រៃ | $13.50 | $16.50 |
| $500 | យកកម្រៃ | $16.00 | $17.00 |
| $1000 | យកកម្រៃ | $25.00 | $26.00 |
| $1500 | យកកម្រៃ | $35.00 | $36.00 |
| $2000 | យកកម្រៃ | $42.00 | $43.00 |
| $2200 | យកកម្រៃ | $46.00 | $47.00 |

សូមកុំភ្លេចទាក់ទងការិយាល័យក្រុមហ៊ុន ABC ដែលនៅជិតលោកអ្នក ប្រសិនបើមានបំណងចង់ផ្ញើប្រាក់ទៅស្រុកខ្មែរ ឬក៏ទូរស័ព្ទមកយើងតាម

### នៅរដ្ឋ VIRGINIA សូមទាក់ទង

**ABC MONEY TRANSATION ,INC.**

8 locations to serve you in Virginia

- 6757 Willson Blvd.-Ste.#25 Tel : 703.534.2600
- 4291 Holland Rd-Ste.#111 Tel : 757.474.9400
- 10428 Ridgefield Pkwy Tel : 804-740-2454
- 2519 W . Mercury Blvd . Tel : 757.265.6305
- 23520 Overland Dr. Tel : 703.661.6666
- 6314 Rigsby Rd. Tel : 804.288.2988
- 7252 Arlingston Blvd . Tel : 703.641.0778
- 6217 W. Broad St. Tel : 804.288.6988

**ARIZONA**
- 4215 N 19th Ave. . Tel : 602.266.6744

**GEOERGIA**
- 4897 Buford Hwy. Ste. 202. Tel: 770.457.7888

**ILLINOIS**
- 4871 N. Broadway . Tel :773.989.7332

**MASSACHUSETTE**
- 996 Dorchester Ave. Tel:617.825.9380
- 1365-1377 Dorchester Ave. -Ste.4,Froor 1 .Tel : 617.265.4600

**MINNESOTA**
- 2718 Nicollet Ave . S.- Ste. 102 B
- Tel : 612.871.4731
- 6350 Brooklyn Blvd . Tel : 763.503.3947

**NORTH CAROLINA**
- 3000 Central Ave. Ste . #9 . Tel : 704-532-4420

**OREGON**
- 6908 N.E. Sandy Blvd . Tel : 503.281.8088

**PHILADFELPHIA**
- 5520 . Whitaker Ave. -Unit 2 . Tel : 215.831.9794
- 571 Adams Ave . Ave.#4 . Tel : 215.342.6623

**TEXAS**
- 1818 E . Pioneer Pkwy. Ste.156 . Tel : 317.461.1461
- 2615 W . Pioneer Pkwy. Ste.136 . Tel : 214.788.2817
- 5302 E . Belknap St.- Ste.D6 . Tel : 817.831.4836
- 3538 W . Walnut St. Tel : 972.272.2253
- 11205 Bellaire Blvd . Tel : 281.561.6600
- 10909 Scarsdale Blvd . Tel : 281.481.2700
- 13480 Veterans Memorial Dr.-Ste. F2. Tel: 281.587.0807

**WASHINTON STATE**
- 766 S.38th St,. Tel : 253.475.2847
- 3818 S.Graham St.-Ste. C Tel : 206.721.2070

Office : 714-590-8740 Fax : 714-590-8776
Cell: 714-603-3509 Toll Free : 1-877-939-0110

## ក្រុមហ៊ុនទទួលផ្ញើប្រាក់ទៅកម្ពុជា

ABC ជាក្រុមហ៊ុនផ្ញើប្រាក់តែមួយគត់នៅស្រុកខ្មែរ ដែលមានការប្រគល់ប្រាក់ដល់ផ្ទះ

- ស្របច្បាប់
- រហ័សទាន់ចិត្ត
- ធានារ៉ាប់រង និងជូនប្រាក់ទៅដល់ផ្ទះ
- កំរៃផ្ញើថោកជាងកន្លែងដទៃ

### ក្រៅពីការផ្ញើប្រាក់ក្រុមហ៊ុនមានលក់

PHONE CARD និង PINLESS សំរាប់ទូរស័ព្ទទៅស្រុកខ្មែរ ដែលផលិតដោយក្រុមហ៊ុន ABC ផ្ទាល់ មានគុណភាពល្អ ហើយជាពិសេស CARD របស់យើងនឹងទុកបានរហូត មិនអស់កំណត់កាលឡើយ ( NEVER EXPIRED) ។

ត្រូវការអ្នកសហការ (AGENTS ) ជាមួយយើងទូទាំងសហរដ្ឋអាមេរិក និងបានទទួលប្រាក់ចំណូលយ៉ាងខ្ពស់ !

ព័តិមានបន្ថែមសូមទាក់ទង CHET THACTHER តាមទូរស័ព្ទ និងអាស័យដ្ឋានខាងក្រោម :

ABC MONEY TRANSATION, INC
12019 Garden Grove Blvd., Ste.#204
Garden Grove , CA 92843
chesterthatcher@yahoo.com

# ហឹង្សានៅសាលាហ្វីឡាដែលហៀវខាងត្បូងសេចក្តីរាយការណ៍គួរឱ្យតក់ស្លុត

•••ក្តីសេចក្តីរាយការណ៍ ៣១ទំព័រ របស់ចៅក្រម ជេម ធី ជីល ដែលចេញផ្សាយជាសាធារណៈ កាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១០ កន្លងទៅស្តីពីការវាយតបលើសិស្សអាស៊ី ចិន និងយួន នៅសាលាហ្វីឡាខាងត្បូង កាលពីថ្ងៃទី៣ ខែធ្នូ បានសរសេរថា "ស្ត្រីខ្មែរម្នាក់ បានផ្តើមវាយមុនគេ ហើយបានបង្ហាញនូវភាពកាចសាហាវជាងគេ..." ។

នៅក្នុងសេចក្តីរាយការណ៍ ដែលរំលឹកដល់សកម្មភាពហឹង្សារបស់ស្ត្រីវ័យក្មេងខ្មែរ នោះជាច្រើនដងបានធ្វើឱ្យមាតាបិតានៃសហគមន៍គ្រប់ពណ៌សម្បុរភ្ញាក់ផ្អើលជាខ្លាំង ។ ចៅក្រម "ជេម" បានចង្អុលពីអំពើហឹង្សានៃពូជសាសន៍ខុសគ្នា ដែលម្ខាងមានក្រុមស្បែកខ្មៅភាគច្រើន ហើយក៏មានខ្មែរ និងយុវជនស្បែកសដែរ ហើយម្ខាងទៀតមានសិស្សចិន និងយួនប្រមាណ ១០០នាក់ បានទទួលការវាយតបយ៉ាងកាចសាហាវពីក្រុមទី១ ។ ការប្រទូសរ៉ាយនេះបានផ្តើមឡើងនៅថ្ងៃទី២ ខែធ្នូ (មុន១ថ្ងៃ) មានការឈ្លោះគ្នារវាងក្រុមអាស៊ី និងក្រុមអាមេរិកាំង ស្បែកខ្មៅ នៅជ្រុងផ្លូវ "ប្រ៊ត" និង "ស្នាយដឺរ" បណ្តាលឱ្យសិស្សពិការស្បែកខ្មៅម្នាក់រងគ្រោះ ។ ស្អែកឡើងនៅក្នុងសាលាក្រុមស្បែកខ្មៅ បានទៅរុករកមុខសិស្សអាស៊ីតាមថ្នាក់ ដើម្បីសងសឹក -មានការលើកគ្នាមកវាយសិស្សអាស៊ីតាមផ្លូវទៅថ្នាក់រៀន តាមអាហារដ្ឋានសាលា ។ អ្នកគ្រូ "ឡសុន" បានចេញមុខការពារ ដោយរងការវាយប្រហារលើសិស្ស អាស៊ីតែម្នាក់ឯង - ពុំមានឃើញសញ្ញានៃការខិតខំទប់ស្កាត់ការវាយតបគ្នាក្រៅពីអ្នកគ្រូ "ឡសុន" ទេ ទោះជាក្រុមអ្នកធ្វើការនៅអាហារដ្ឋានក៏ដូចជា នាយកសាលា "ឡាក្រេតា ប្រោឥន" ក៏ដោយ ។ ចៅក្រម "ជេម" បានសរសេរថា ការវាយគ្នានេះ មានការរៀបចំ ហើយគ្រោងទុកជាមុន ហើយសិស្សអាស៊ីមានការភ័យខ្លាច ហើយបានសុំឱ្យមានការជូនសិស្សទៅផ្ទះពេលចេញពីសាលាវិញ" ។

សេចក្តីរាយការណ៍បានបញ្ជាក់ថា "មានការប្រកាន់ពណ៌សម្បុរស្បែក តែពុំអាចបញ្ជាក់ឱ្យបានច្បាស់លាស់ថា ការវាយប្រហារនេះ ដោយសារតែក្រុមអាស៊ីជាជនអន្តោប្រវេសន៍ " ។



On Wednesday, December 13th, 2009, Students from South Philly High told the School Reform Commission what they think.

នៅវិទ្យាល័យហ្វីឡាដែលហៀវខាងត្បូងនេះ មានប្រវត្តិទទួលបណ្តឹងអំពើហឹង្សាយ៉ាងវែងលើសិស្សអន្តោប្រវេសន៍ តែក្រុមប៉ូលិសការពារសន្តិសុខបានរាយការណ៍ថា វិទ្យាល័យមួយនេះ មានជាប់ទាក់ទងនឹងក្រុម "ជនពាល" ផងដែរ ។

ក្រុមមាតាបិតាសិស្សអាស៊ី បានដាក់ពាក្យប្តឹងសាលារៀន ចេញពី "ឆាយណាថោន" ស្តីអំពីការមិនយកចិត្តទុកដាក់ បណ្តាលឱ្យមានគ្រោះថ្នាក់ទៅតុលាការ ហើយសេចក្តីរាយការណ៍នេះ អាចនឹងត្រូវគេបកស្រាយថា ជាជម្លោះរវាងសិស្សអាស៊ី និងសិស្សអាស៊ីគ្នាឯងទៅវិញបាន ។ ក្រុមមាតាបិតាខ្មែរធ្លាប់និយាយថា "បញ្ហាកូនសិស្សស្បែកខ្មៅវាយលើកូនខ្មែរនេះ ក៏មានជារឿយៗ តាំងពីច្រើនឆ្នាំមកហើយ បណ្តាលឱ្យកូនខ្លួនខ្លាចការទៅរៀនជាខ្លាំងនៅហ្វីឡាដែលហៀវនេះ តែពុំដែលមានអាជ្ញាធរណាឬអង្គការណាយកចិត្តទុកដាក់នោះទេ" - កាលពីឆ្នាំមុន ក្រុមដដែលនេះ បានថ្លែងប្រាប់សាលាក្រុង អំពីកង្វល់សន្តិសុខកូនសិស្សខ្មែរដែរ តែពុំមានទទួលចម្លើយណាមួយមកវិញទេ ។

ព្រឹត្តិការណ៍ដែលកើតឡើងបណ្តាលឱ្យរបួសសិស្សចិន និងយួនច្រើននាក់ នាចន្លោះថ្ងៃទី២ និងទី៣ ខែធ្នូ ឆ្នាំ២០០៩ នោះ បាននាំឱ្យមានសេចក្តីសម្រេចឱ្យសិស្ស ២២ រូប ត្រូវព្យួរជើង ហើយខ្លះទៀតត្រូវបណ្តេញចេញពីសាលា ហើយខ្លះទៀតត្រូវទទួលការចោទប្រកាន់ពីតុលាការពីបទឧក្រិដ្ឋទៀតផង ៕

-ខ្មែរប៉ុស្តិ៍-

## ពាណិជ្ជកម្មនាំចេញខ្មែរមានឱនភាព



ដោយ : ដាណាលី

•••នាឆ្នាំ២០០៩ សេចក្តីរាយការណ៍ពីការនាំសម្លៀកបំពាក់ចេញទៅក្រៅបានតិចជាងឆ្នាំមុនៗ ដែលទទួលកំរៃបាន២.៦ពាន់លានទល់នឹង៣ពាន់១លានកាលពីឆ្នាំ ២០០៩ ។ ដូចគ្នានឹងការនាំសម្លៀកបំពាក់ចូលមកសហរដ្ឋអាមេរិកបានកំរៃ១.៥ពាន់លានដុល្លារ នៅឆ្នាំ ២០០៩ ដល់២ពាន់លានដុល្លារកាលពីឆ្នាំ ២០០៨។

ការធ្លាក់ចុះប្រាក់ចំណូលពីការនាំចេញនៅកម្ពុជាបានត្រូវគេឃើញកើនការនាំចេញទៅប្រទេសផ្សេងប្រមាណ២៣៣លានដុល្លារ ដាណាលី ធ្វើសេចក្តីរាយការណ៍ជាភាសាអង់គ្លេសដូចតទៅនេះ :

Writer: Dannaly Sam
The Khmer Post

PHNOM PENH – Exports of garments from Cambodia have decreased in 2009 with a profit of only 2.6 billion dollars in comparison with 3.1 billion dollars in 2008, as cited by Xinhua General News Service from the Commerce Ministry on February 23, 2010.

Cambodia's garment export reached the United States in 2009 with 1.5 billion dollars in comparison with close to 2 billion dollars in 2008.

The reported released by the Commerce Ministry also stated that the garment export to the European Union also decreased by sixty-eight billion dollars from 2008 in 2009.

With drops in Cambodian garment exports to countries in Europe, the U.S., and Canada, there has been a jump in exports to other countries in Asia with a jump in 233 million dollars in 2009 versus the 178 million dollars in 2008.

NEW PHNOM PENH RESTAURANT
○មីបំពងគ្រឿងសមុទ្រ ○គុយទាវគោក -គុយទាវសាច់គោ
○ផាត់ថៃ ○ឡុកឡាក់ ○មាន់ឆាខ្ញី
○បាយសាច់ជ្រូកអាំង ○មីកន្ត្នាំងសាច់គោ ○បាយឆាសាច់គ្រប់មុខ

TEL.(215) 389-2122
2301 South. 7th Street. Philadelphia, PA 19148
( 7th & Wolf)

FRANK'S TIRES


2624 S. FAIRHILL ST.
(215) 334-2261
OPE N 7 DAYS A WEEK
8 A.M. – 7 P.M.
NEW & USED TIRES
ESTBLISHED SINCE 1984

Nationwide
Insurance & Financial Service
សេវាធានារ៉ាប់រង និងហិរញ្ញវត្ថុ
We offer Cheap Price for Every Client
យើងធ្វើជូនគ្រប់គ្នៀវដោយតម្លៃទាប
Business Liability Insurance ធានារ៉ាប់រងជំនួញលោកអ្នក
Home Insurance ធានារ៉ាប់រងផ្ទះសម្បែង
Health Insurance ធានារ៉ាប់រងសុខភាព
Auto Insurance ធានារ៉ាប់រងរថយន្ត
Life Insurance ធានារ៉ាប់រងជីវិត
Discount 30% when you purchase Home & Auto Insurance
ចុះតម្លៃ ៣០ % បន្ថែមបើលោកអ្នកទិញ ធានារ៉ាប់រងផ្ទះ និងរថយន្តរួមគ្នា
South Philadelphia office:
600 Washington Ave Suite #8
Philadelphia, Pa 19147
Tel: (215) 463-1257
Fax: (215) 463-2036
North Philadelphia office:
6603 Bustleton Ave.
Philadelphia, Pa 19149
Tel: (215) 335-2140
Fax: (215) 335-2147

# HONG KONG
## SUPERMARKET

## FAMER´S BEST




$1.69/can


$3.49 each

**Newly Renovated.**
**Added new section .**
**Clean and Improved management !**

ទើបនឹងកែលំអរថ្មីឡើងវិញ
-បន្ថែមផ្នែកលក់ថ្មីទៀត
បាងស្អាត ហើយបង្កើន
គុណភាពគ្រប់គ្រង

**Weekly Sale**
លក់ចុះថ្លៃរៀងរាល់សប្តាហ៏


$2.99/bag


$7.99


$2.99




$6.99/box


$1.29/can


$2.49/28oz


$2.49/bag


2 for $3


$4.99 / lb

**OPEN 7 DAY 8:00 - 9:00**

571 ADAMS AVE.PHILADELPHIA,PA19120
Tel: 215-7281300 Fax: 215-728-1600

- ចំណាយ **$140**ដុល្លារ ទទួលបានអង្ករស្រូវស ២៥ ផោន
- ចំណាយ **$100**ដុល្លារ ទទួលបានទូរភេសជ្ជ: ឬទឹកញ្ជប់មួយប្រអប់( តម្លៃ **8.99**)
- ចំណាយ **$25** ដុល្លារទទួលបានទឹកសណ្តែកមួយដប ឬទឹកត្រីមួយដប ។



CAMBODIAN ASSOCIATION OF GREATER PHILADELPHIA, INC.
CAMBODIAN
New Year Celebration
Our Children...Our Future
Saturday, April 10th, 2010
5:30 to 11 PM
Regal Ballroom
5411 Oxford Avenue
Philadelphia, PA 19124
Ticket $55, but $50 if purchased by March 31.
Featuring live band "The Golden Eagle," cultural performances, social dancing, buffet dinner and more!
Call 215-324-4070 to order tickets.
Proceeds benefit CAGP's Youth Culture and Capacity Building Project.
សួស្តីឆ្នាំថ្មី
ថ្ងៃសៅរ៍ ទី១០ ខែ មេសា ឆ្នាំ ២០១០
ម៉ោង ៥:៣០ល្ងាច ដល់ម៉ោង ១១យប់
ទូរសព្ទមកលេខ ២១៥-៣២៤-៤០៧០
ដើម្បីទិញសំបុត្រ
សំបុត្រមួយ៥៥ដុល្លា (តែបើទិញមុនថ្ងៃ ទី៣១ ខែ
មិនា សំបុត្រមួយ៥០ដុល្លា)
មានរបាំប្រពៃណីនិងរាំកំសាន្តជាមួយវង់តន្ត្រីសម័យតន្ត្រីមាស
មានម្ហូបទទួល




Yoo's Auto Service and Collision
យូ បំរើសេវារថយន្ត
នឹងរថយន្តគ្រោះថ្នាក់ប៉ះទង្គិច
ពេទ្យជាងម៉ាស៊ីន
Check Engine Light Diagnostic
Electronic Wheel Alignment
Certified Enhanced Emission
Inspection & Repairs
Muffler & More
FREE ESTIMATES
យើងនឹងជួសជុលរថយន្តដ៏មានតម្លៃរបស់លោកអ្នក ឱ្យបានប្រសើរបំផុត
តាមតែយើងធ្វើបាន ដើម្បីសុវត្ថិភាពលោកអ្នក មិនឱ្យខុសចិត្តឡើយ ។
COUPON
$10 OFF TOWARD EMISSION AND STATE INSPECTION
ពេទ្យជួសជុលតួរថយន្ត
Expert Body Work
Fender & Paint Work
Frame Straightening
Insurance Specialists
ឧបករណ៍ទំនើបទាន់សម័យ
ទូរស័ព្ទលេខ SAM 215-457-7777 ឬ 215-457-7779, Fax-215-457-7475
189 W. Duncannon Ave. Phila., PA 19120





# Census Jobs

**Apply Now!**

United States Census 2010
It's In Our Hands

## Don't miss this opportunity.

**Temporary, part-time jobs that offer good pay, flexible hours, and are close to home.**

Census Taker
Crew Leader
Crew Leader Assistant
Call today to be scheduled for our test!

www.2010censusjobs.gov
1-866-861-2010

FedRelay: 1-800-877-8339 TTY
The U.S. Census Bureau is an Equal Opportunity Employer.

Kavei

# ភោជនីយដ្ឋានខ្មែរ

320 OREGON AVENUE . PHILADELPHIA PA 19148 . 215-952-6688



នំបញ្ចុកសម្លខ្មែរ